# ព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម




ឆ្នាំទី៣១ លេខ៧៤២ ខែកក្កដា ឆ្នាំ២០២៤

# មាតិកា


## ០១ ស្ថិតិពាណិជ្ជកម្ម

១.១. សន្ទស្សន៍ថ្លៃទំនិញនៅលើទីផ្សាររាជធានីភ្នំពេញប្រចាំខែកក្កដា ឆ្នាំ២០២៤........................................០១
១.២. ការចុះបញ្ជីសហគ្រាសពាណិជ្ជកម្ម.............................................................................................០៣
១.៣. ការចុះបញ្ជីម៉ាកពាណិជ្ជនាម.....................................................................................................០៥
១.៤. វិស័យនាំចេញរបស់កម្ពុជា.........................................................................................................០៧
១.៥. តម្លៃទំនិញប្រើប្រាស់ចាំបាច់សំខាន់ៗលើទីផ្សារអន្តរជាតិប្រចាំខែកក្កដា ឆ្នាំ២០២៤...........................១១

## ០២ អត្ថបទស្រាវជ្រាវ

ទីផ្សារសូត្រកម្ពុជា.........................................................................................................................១៦

## ០៣ ព័ត៌មានរបស់ក្រសួងពាណិជ្ជកម្ម

សកម្មភាពថ្នាក់ដឹកនាំ...................................................................................................................១៨

## ០៤ ព័ត៌មានទីផ្សារអន្តរជាតិ

ទីផ្សារនាំចេញទំនិញវៀតណាមឆ្នាំ២០២៣៖....................................................................................២០

# ១-ស្ថិតិពាណិជ្ជកម្ម

## ◆ ១.១ សន្ទស្សន៍ថ្លៃទំនិញ នៅលើទីផ្សាររាជធានីភ្នំពេញ៖

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ប្រចាំជីវភាព នៅលើទីផ្សាររាជធានីភ្នំពេញប្រចាំខែកក្កដា ឆ្នាំ២០២៤មានដូចជា៖(នៅលើទីផ្សារធំថ្មី, កណ្តាល, ច្បារអំពៅ, ដើមគរ និងផ្សារអូរឫស្សី)។

- តារាងប្រៀបធៀបសន្ទស្សន៍តម្លៃទំនិញប្រចាំជីវភាពនៅលើទីផ្សារ (ឯកតា៖ គិតជារៀល)

| មុខទំនិញ | ឯកតា | ខែមិថុនា ឆ្នាំ២០២៤ | ខែកក្កដា ឆ្នាំ២០២៤ | កើន (+) ថយ (-) | ភាគរយ (%) |
|---|---|---|---|---|---|
| អង្ករផ្កាម្លិះ | គីឡូ/រៀល | 4,000 | 3,800 | -200 | -0.05 |
| អង្ករនាងម៉ិញ | គីឡូ/រៀល | 3,000 | 3,000 | - | - |
| សាច់គោ | គីឡូ/រៀល | 3,8000 | 38,000 | - | - |
| សាច់ជ្រូក | គីឡូ/រៀល | 20,000 | 20,000 | - | - |
| សាច់មាន់ | គីឡូ/រៀល | 27,000 | 27,000 | - | - |
| ត្រីរ៉ស់ស្រស់ | គីឡូ/រៀល | 12,500 | 12,500 | - | - |

- តម្លៃអង្ករ៖ តម្លៃអង្ករលក់នៅលើទីផ្សារទាំង៥ ក្នុងរាជធានីភ្នំពេញ សម្រាប់ខែកក្កដា ប្រៀបធៀបទៅនឹងខែមិថុនា ឆ្នាំ២០២៤ នេះឃើញថាតម្លៃអង្ករផ្កាម្លិះមានការថយចុះ ០,០៥ និងអង្ករនាងម៉ិញមានការថេរដូចគ្នា។
- តម្លៃម្ហូបអាហារ៖ តម្លៃម្ហូបអាហារ នៅលើទីផ្សារទាំង៥ក្នុងរាជធានីភ្នំពេញ សម្រាប់ខែកក្កដា បើធៀបទៅនឹងខែមិថុនា ឆ្នាំ២០២៤ ពុំមានការប្រែប្រួលទៅលើមុខទំនិញដូចជា៖ សាច់គោ សាច់ជ្រូក សាច់មាន់ និងត្រីរ៉ស់ស្រស់។

- រីឯនៅលើទីផ្សារអន្តរជាតិនៅក្នុងខែកក្កដានេះ តម្លៃអង្ករនាំចេញនៅទីផ្សារមានការប្រែប្រួលទៅតាមតំបន់ តម្លៃអង្ករនាំចេញប្រទេសជិតខាងវៀតណាម និងប្រទេសថៃមានការថយចុះ ដោយសារឈ្មួញអង្ករវង់ចាំការអនុវត្តច្បាប់នាំចូលអង្ករថ្មី ក្រោយពីមានការកែប្រែពីប្រទេសនាំចូលច្រើននៅលើពិភពលោក (ហ្វីលីពីន)។ ខណៈនេះដែរតម្លៃដឹកជញ្ជូនក៏កើនឡើងបានជះឥទ្ធិពលដល់តម្រូវការទិញអង្ករវណ្ណាពីអតិថិជននៅទ្វីបអាហ្វ្រិកផងដែរ។

ប្រភព៖ Webside vinanet



- **តម្លៃប្រេងឥន្ធនៈ**

តារាងប្រៀបធៀបសន្ទស្សន៍តម្លៃប្រេងឥន្ធនៈនៅលើទីផ្សារ

(ឯកតា៖ គិតជារៀល)

| ប្រភេទ | ឯកតា | ខែមិថុនា ឆ្នាំ២០២៤ | ខែកក្កដា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| សាំងស៊ុបពែ | លីត្រ/រៀល | 4,800 | 4,950 | 150 | 0.03 |
| សាំងធម្មតា | លីត្រ/រៀល | 4,200 | 4,300 | 100 | 0.02 |
| ប្រេងម៉ាស៊ូត | លីត្រ/រៀល | 4,150 | 4,200 | 50 | 0.01 |
| ហ្គាស | ១៥គីឡូ/រៀល | 70,000 | 70,000 | - | - |







- ប្រេងឥន្ធនៈ៖ តម្លៃប្រេងឥន្ធនៈនៅបណ្តាស្ថានីយ៍ក្រុមហ៊ុនទាំង៩ របស់កម្ពុជាដូចជា ក្រុមហ៊ុនកម្ពុជាតេលា សូគីម៉ិច ភីធីធី តូតាល់ ឈេហ្វ្រុន សាវីម៉ិច ប៊ីវីអឹម អិលអេចអរ និងក្រុមហ៊ុនប៉ាប៉ា ក្នុងបណ្តារាជធានីភ្នំពេញ-ខេត្ត សម្រាប់ខែកក្កដា ធៀបទៅនឹងខែមិថុនា ឆ្នាំ២០២៤ តម្លៃសាំងស៊ុបពែបានកើន ០,០៣%, សាំងធម្មតាបានកើន ០,០២% និងប្រេងម៉ាស៊ូតបានកើន ០,០១% និងតម្លៃហ្គាសមានសភាពថេរ។

- តម្រូវការប្រើប្រាស់ប្រេងឆៅ នៅទីផ្សារក្រុងញ៉ូយកតម្លៃប្រាក់ដុល្លារអាមេរិកបានកើនឡើងក្នុងតម្លៃមួយខ្ពស់ ធៀបទៅនឹងរូបិយប័ណ្ណមានតម្លៃរបស់ប្រទេសមួយចំនួន ដែលជាមូលហេតុបណ្តាលឲ្យតម្រូវការប្រើប្រាស់ប្រេងថយចុះ។ ទន្ទឹមនឹងនេះដែរតាមតួលេខស្ថិតិបានបង្ហាញថាខឿនសេដ្ឋកិច្ចប្រទេសចិនទទួលបានកំនើនទាបជាង ៤,៧%នៅក្នុងត្រីមាសទី២ បានបង្កើននូវសេចក្តីព្រួយបារម្ភអំពីតម្រូវការប្រើប្រាស់ប្រេងរបស់ប្រទេសចិននេះ។

ប្រភព៖ Website Vinanet

## ១.២ ការចុះបញ្ជីសហគ្រាសពាណិជ្ជកម្ម

- តារាងប្រៀបធៀបចំនួនក្រុមហ៊ុន ដែលបានចុះបញ្ជីពាណិជ្ជកម្មក្នុងខែកក្កដា ធៀបទៅនឹងខែមិថុនា ឆ្នាំ២០២៤

(ឯកតា៖ ចំនួនក្រុមហ៊ុន)

| ប្រភេទក្រុមហ៊ុន | ខែមិថុនា ឆ្នាំ២០២៤ | ខែកក្កដា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|
| **ករណីស្នើសុំចុះបញ្ជីពាណិជ្ជកម្ម(ថ្មី)** | | | | |
| ក្រុមហ៊ុនមូលធន | 461 | 441 | -20 | -0.04 |
| ក្រុមហ៊ុនពាណិជ្ជកម្មបរទេស | 8 | 4 | -4 | -0.50 |
| សហគ្រាសឯកបុគ្គល | 451 | 427 | -24 | -0.05 |
| **ករណីស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក** | | | | |
| លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | 1 | 1 | - | - |
| លិខិតអនុញ្ញាតសហគ្រាសឯកបុគ្គល | 2 | 1 | -1 | -0.50 |
| អាជ្ញាបណ្ណ | - | 2 | 2 | 100 |
| **ករណីស្នើសុំលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម** | | | | |
| ក្រុមហ៊ុនមូលធន | 86 | 114 | 28 | 0.33 |
| ក្រុមហ៊ុនពាណិជ្ជកម្មបរទេស | 2 | 2 | - | - |
| សហគ្រាសឯកបុគ្គល | 20 | 17 | -3 | -0.15 |
| **ករណីស្នើសុំចុះបញ្ជីកែប្រែ** | | | | |
| កែប្រែប្តូរភាគហ៊ុន បន្ថយបង្កើនដើមទុន | 193 | 193 | - | - |
| ការកែប្រែផ្សេងៗ (អភិបាល កម្មវត្ថុ .....) | 952 | 986 | 34 | 0.04 |
| ការបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក | 37 | 37 | - | - |
| ការកែប្រែសហគ្រាសឯកបុគ្គល | 56 | 67 | 11 | 0.20 |

## ក្រាហ្វិកករណីស្នើសុំចុះបញ្ជីពាណិជ្ជកម្ម (ថ្មី)




## ក្រាហ្វិកករណីស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក




## ក្រាហ្វិកករណីស្នើសុំលុបឈ្មោះ




## ក្រាហ្វិកស្នើសុំចុះបញ្ជីកែប្រែ



## ១.៣ ការចុះបញ្ជីម៉ាកពាណិជ្ជនាមៈ

- តារាងប្រៀបធៀបចំនួនម៉ាកពាណិជ្ជនាមដែលបានចុះបញ្ជីនៅក្នុងខែកក្កដា ធៀបទៅនឹងខែមិថុនា ឆ្នាំ២០២៤

(ឯកតា៖ គិតជាចំនួនម៉ាក)

| ការផ្តល់សេវាផ្សេងៗ ពាក់ព័ន្ធ និងកិច្ចការពារម៉ាក | ខែមិថុនា ឆ្នាំ២០២៤ | ខែកក្កដា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|
| **ការចុះបញ្ជីម៉ាកពាណិជ្ជនាម**(Registration) | | | | |
| ក្នុងស្រុក | 99 | 194 | 95 | 0.96 |
| ក្រៅស្រុក | 45 | 223 | 178 | 3.96 |
| ការបដិសេធចុងក្រោយ និងបោះបង់ចោល | 22 | 64 | | 1.91 |
| ការស្នើផ្លាស់ប្តូរម៉ាក | 18 | 12 | -6 | -0.33 |
| ការស្នើផ្លាស់ប្តូរទំនិញ រឺសេវ៉ា | 4 | 8 | 4 | 1.00 |
| ការស្នើផ្លាស់ប្តូរឈ្មោះអ្នកស្នើសុំ | 1 | - | -1 | -1.00 |
| ការស្នើផ្លាស់ប្តូរអាសយដ្ឋាន | - | - | - | - |
| ការស្នើផ្លាស់ប្តូរសុំពន្យារពេល | 36 | 15 | -21 | -0.58 |
| **ការចុះបញ្ជីម៉ាកតាមប្រព័ន្ធអន្តរជាតិ** (Madrid system) | | | | |
| សុំចុះបញ្ជីម៉ាកពីប្រទេសហត្ថលេខីតាមប្រព័ន្ធចុះបញ្ជីម៉ាកអន្តរជាតិ | 232 | 213 | -19 | -0.08 |
| ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអន្តរជាតិ(Madrid system) | 187 | 209 | 22 | 0.12 |
| ការផ្លាស់ប្តូរផ្សេងៗតាមប្រព័ន្ធអន្តរជាតិ (Madrid system) | 56 | 174 | 118 | 2.11 |

**ក្រាហ្វិកការចុះបញ្ជីម៉ាកពាណិជ្ជនាម** ( Registration )




ខែមិថុនា ឆ្នាំ២០២៤
ខែកក្កដា ឆ្នាំ២០២៤

**ការចុះបញ្ជីម៉ាកតាមប្រព័ន្ធអន្តរជាតិ** ( Madrid system )



## ១.៤ ទិស័យនាំចេញរបស់កម្ពុជា

- **ការនាំចេញផលិតផលពីកម្ពុជា ទៅបណ្ដាប្រទេសក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី**( Cambodian Export Under FTA GSP and MFN Scheme )

តារាងប្រៀបធៀបតម្លៃផលិតផលនាំចេញពីកម្ពុជាទៅបណ្ដាប្រទេស ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

( ឯកតា៖ ដុល្លារអាម៉េរិក )

| ប្រភេទទំនិញ | ខ្នាត | ខែមិថុនា ឆ្នាំ២០២៤ | ខែកក្កដា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| សំលៀកបំពាក់ | DOZ | 3,323,698,456 | 777,827,376 | -2,545,871,080 | -0.77 |
| វាយនភ័ណ្ឌ | N/A | 45,120,354 | 9,180,784 | -35,939,570 | -0.80 |
| ស្បែកជើង | PRS | 693,732,698 | 148,164,459 | -545,568,239 | -0.79 |
| កាបូបធ្វើដំណើរ | DOZ | 753,407,025 | 159,566,257 | -593,840,768 | -0.79 |
| កង់ | SET | 152,718,251 | 30,856,379 | -121,861,872 | -0.80 |
| អង្ករ | N/A | 702,616,852 | 91,832,582 | -610,784,270 | -0.87 |
| ទំនិញកសិកម្ម | - | 2,572,932,431 | 123,914,880 | -2,449,017,571 | -0.95 |
| ផលិតផលផ្សេងៗ | N/A | 2,927,657,214 | 773,285,274 | -2,154,371,940 | -0.74 |
| **សរុបរួម** | | **11,171,983,280** | **11,171,983,280** | **-9,057,255,310** | **-5.68** |

- ប្រភពនាយកដ្ឋាននាំចេញ នាំចូល៖ តួលេខនាំចេញនេះ ជាតួលេខដែលទទួលបានក្រោមការផ្ដល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ។

## ក្រាហ្វិកតម្លៃផលិតផលនាំចេញពីកម្ពុជាទៅបណ្តាប្រទេស ក្រោមប្រព័ន្ធ អនុគ្រោះពាណិជ្ជកម្ម និងពាណិជ្ជកម្មសេរី លើទីផ្សារពិភពលោក






- **ប្រទេសនាំចេញទំនិញពីកម្ពុជា ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី**( Cambodian Export Under FTA GSP and MFN Scheme )

តារាងប្រៀបធៀបប្រទេសនាំចេញតម្លៃទំនិញពីកម្ពុជាទៅបណ្តាប្រទេស ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនិងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (ឯកតា៖ ដុល្លារអាមេរិក)

| ប្រទេស | ខែមិថុនា ២០២៤ | ខែកក្កដា ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|
| អាមេរិក | 3,332,503,215 | 838,752,228 | -2,493,750,987 | -0.75 |
| អង់គ្លេស | 354,123,924 | 155,149,325 | -198,974,599 | -0.56 |
| សហគមន៍អឺរ៉ុប | 1,364,482,790 | 285,453,582 | -1,079,029,208 | -0.79 |
| កាណាដា | 425,851,854 | 91,873,417 | -333,978,437 | -0.78 |
| អាស៊ាន | 3,709,119,837 | 369,067,842 | -3,340,051,995 | -0.90 |
| ជប៉ុន | 582,417,104 | 88,218,235 | -494,198,869 | -0.85 |
| ចិន | 695,343,189 | 149,185,971 | -546,157,218 | -0.79 |
| អូស្ត្រាលី | 84,086,110 | 15,698,294 | -68,387,816 | -0.81 |
| ឥណ្ឌា | 92,712,652 | 22,360,822 | -70,351,830 | -0.76 |
| ណូវែលហ្សេឡង់ | 9,289,376 | 1,707,367 | -7582,009 | -0.82 |
| អារ៉ាប៊ីសាអូឌីត | 30,626,429 | 5,828,058 | -24,798,371 | -0.81 |
| កូរ៉េ | 146,413,756 | 25,202,385 | -121,211,371 | -0.83 |
| បណ្តាប្រទេសផ្សេងៗក្នុងពិភពលោក | 345,013,046 | 66,130,444 | -278,882,602 | -0.81 |
| **សរុបរួម** | **11,171,983,382** | **2,114,627,971** | **-9,057,355,312** | **-0.81** |

- ប្រភពនាយកដ្ឋាននាំចេញ នាំចូល៖ តួលេខនាំចេញនេះ ជាតួលេខដែលទទួលបាន ក្រោមការផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ។

## ក្រាហ្វិកការនាំចេញរបស់កម្ពុជា






## ១.៥ តម្លៃទំនិញប្រើប្រាស់ចាំបាច់សំខាន់ៗ លើទីផ្សារអន្តរជាតិប្រចាំខែកក្កដា ឆ្នាំ២០២៤

- **អង្ករ៖**

(ឯកតា៖ ដុល្លារអាមេរិក/តោន)

| មុខទំនិញ | លក្ខខណ្ឌ ប្រគល់-ទទួល | ខែមិថុនា ឆ្នាំ២០២៤ | ខែកក្កដា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| អង្ករប្រភេទបាក់5% | FOB Bangkok | 602 | 578 | -24 | - 3.99 |
| អង្ករប្រភេទបាក់5% | FOB Vietnam | 567 | 551 | -16 | -2.82 |
| អង្ករប្រភេទបាក់5% | FOB India | 555 | 555 | - | - |
| អង្ករប្រភេទបាក់5% | FOB មីយ៉ាន់ម៉ា | 582 | 573 | -9 | -1.55 |
| អង្ករប្រភេទបាក់5% | FOB USA | 801 | 822 | 21 | 2.62 |
| អង្ករប្រភេទបាក់5% | FOB ប៉ាគីស្ថាន | 583 | 587 | 4 | 0.69 |
| អង្ករប្រភេទបាក់25% | FOB Bangkok | 550 | 530 | -20 | -3.64 |
| អង្ករប្រភេទបាក់25% | FOB Vietnam | 543 | 522 | -21 | -3.87 |
| អង្ករប្រភេទបាក់25% | FOB India | 540 | 540 | - | - |
| អង្ករក្រហមប្រភេទ (Hommali) 100% | FOB Bangkok | 568 | 545 | -23 | -4.05 |
| អង្ករក្រហមប្រភេទ5% | FOB India | 562 | 562 | - | - |
| អង្ករហ្វូមមាលីប្រភេទ (hommali)100% | FOB Bangkok | 849 | 825 | -24 | -2.83 |
| អង្ករក្រអូប | FOB Vietnam | 630 | 618 | -12 | -1.90 |

- កត់សំគាល់៖ តម្លៃអង្ករលក់ចេញនៅទីផ្សារសំខាន់ៗនៅក្នុងខែកក្កដា ឆ្នាំ២០២៤នេះ គឺមានការប្រែប្រួលធៀបទៅនឹងខែមិថុនា ឆ្នាំ២០២៤។
- នៅក្នុងខែកក្កដានេះ នៅប្រទេសថៃតម្លៃអង្ករនាំចេញបានថយចុះពី ២៣ទៅ២៤ដុល្លារ/តោន(FOB, Bangkok) ធៀបទៅនឹងខែមិថុនា ដោយសារអង្ករប្រភេទបាក់ ៥% លក់ចេញក្នុងតម្លៃ ៥៧៨ដុល្លារ/តោន (FOB, Bangkok) និងអង្ករប្រភេទបាក់២៥% លក់ចេញក្នុងតម្លៃ ៥៣០ដុល្លារ/តោន (FOB, Bangkok) និងអង្ករប្រភេទហូមមាលី ១០០% លក់ចេញក្នុងតម្លៃ ៨២៥ដុល្លារ/តោន (FOB, Bangkok)។
- នៅវៀតណាម តម្លៃអង្ករនាំចេញបានថយចុះពី ១២ទៅ ២១ដុល្លារ/តោន (FOB, កំពង់ផែក្រុងហូជីមិញ) ធៀបខែបន្ទាប់ដោយអង្ករប្រភេទបាក់ ៥% លក់ចេញក្នុងតម្លៃ ៥៥១ដុល្លារ/តោន(FOB, Vietnam) និងអង្ករប្រភេទក្រអូបលក់ចេញក្នុងតម្លៃមធ្យម ៦១៨ដុល្លារ/តោន (FOB, កំពង់ផែក្រុងហូជីមិញ)។ ប្រភេទ២៥% លក់ចេញក្នុងតម្លៃជាមធ្យម ៥២២ដុល្លារ/តោន (FOB, កំពង់ផែក្រុងហូជីមិញ)។ នៅក្នុងខែកក្កដានេះ តម្លៃអង្ករនាំចេញនៅលើទីផ្សារមានការប្រែប្រួលទៅតាមតំបន់ តម្លៃអង្ករនាំចេញរបស់ប្រទេសជិតខាងវៀតណាម និងថៃបានថយចុះដោយសារឈ្មួញអង្កររង់ចាំការអនុវត្តច្បាប់នាំចូលអង្ករថ្មីក្រោយពីមានការកែប្រែពីប្រទេសនាំចូលជាច្រើនលើពិភពលោក(ហ្វីលីពីន)។ ខណៈនេះ តម្លៃដឹកជញ្ជូនកើនឡើងបានជះឥទ្ធិពលដល់តម្រូវការទិញអង្ករឥណ្ឌាពីអតិថិជននៅទ្វីបអាហ្វ្រិកផងដែរ។ ហ្វីលីពីនកំពុងពិនិត្យនិងធ្វើការផ្លាស់ប្តូរគោលនយោបាយនាំចូលអង្ករ និងកាត់បន្ថយលើពន្ធនាំចូលអង្ករ ជាហេតុធ្វើឲ្យឈ្មួញនាំចេញកាត់បន្ថយល្បឿននៃការប្រមូលទិញ។ ប្រភពផ្គត់ផ្គង់ពីការប្រមូលផលស្រូវរដូវថ្មីកំពុងហូរចូលមកកាន់ទីផ្សារនៅក្នុងខែនេះ ហើយអាចនឹងធ្វើឲ្យតម្លៃធ្លាក់ចុះនៅក្នុងខែបន្ទាប់។ បើតាមសារព័ត៌មាន Reuters បានឲ្យដឹងថា៖ ទីផ្សារអង្ករស្ថិតក្នុងស្ថានភាពស្ងប់ស្ងាត់ដោយសារអ្នកទិញកំពុងរង់ចាំច្បាប់កាត់បន្ថយពន្ធ របស់ប្រទេសហ្វីលីពីនមានសុពលភាពសិន។ នៅក្នុងខែកក្កដា តម្លៃនៃការដឹកជញ្ជូនតាមផ្លូវសមុទ្រនៃតំបន់ Baltic បានកើនឡើងដល់តម្លៃខ្ពស់បំផុតធៀបទៅនឹងរយៈពេល២ខែបន្ទាប់។ កាលពីខែមេសាកន្លងទៅ ប្រទេសបង់ក្លាដេសបានប្រកាសអំពីផែនការនាំចូលអង្ករជិត២លានតោន ប៉ុន្តែរហូតមកដល់ពេលនេះពុំទាន់បានសំរេចផែនការនៅឡើយទេ។ តាមការព្យាករណ៍បានឲ្យដឹងថានៅក្នុងឆ្នាំ២០២៤ហ្វីលីពីននឹងនាំចូលអង្ករចំនួន៣,៨ទៅ៣,៩លានតោននិងបន្តជាប្រទេសនាំចូលអង្ករច្រើនបំផុតលើពិភពលោក ហើយប្រទេសឥណ្ឌូនេស៊ីនឹងនាំចូលអង្ករចំនួន ៣,៦លានតោន ចិននាំចូលប្រហែល ១,៩លានតោន តំបន់អាស៊ីខាងលិចនិងទ្វីបអាហ្វ្រិកមានតម្រូវការប្រហែល២,៧លានតោនគឺកើន៦២%ធៀបឆ្នាំ ២០២៣។

- **កសិផល៖** (ឯកតា៖ដុល្លារអាម៉េរិក/តោន)

| មុខទំនិញ | លក្ខខណ្ឌប្រគល់-ទទួល | ខែមិថុនា ឆ្នាំ២០២៤ | ខែកក្កដា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| ស្រូវសាលី | FOB USA | 216.15 | 212.50 | -3.65 | -1.69 |
| ពោត | - | 168.97 | 155.50 | -13.47 | -7.97 |
| សណ្តែកសៀង | - | 411.07 | 406.70 | -4.37 | -1.06 |
| ប្រេងដូងមិនទាន់កែច្នៃ | FOB Malaysia | 830.61 | 847.69 | 17.08 | 2.06 |
| ប្រេងសណ្តែកសៀង | CIF Rotterdam | 975.48 | 975.05 | -0.43 | -0.04 |

| | | | | | |
|---|---|---|---|---|---|
| គ្រាប់ម្រេចខ្មៅ | FOB (V.N) | 3,590 | 3,450 | -140 | -3.90 |
| គ្រាប់ម្រេចស | FOB (V.N) | - | 4,390 | 4,390 | 100 |
| កាហ្វេ ( ROBUSTA ) | FOB New York(USA) | 4,270 | 4,498 | 228 | 5.34 |
| កាហ្វេ ( ARABICA ) | London | 5,072.30 | 5,994.15 | 921.85 | 18.17 |
| កប្បាសលេខ២ | FOB New York | 1,650.50 | 1,601.51 | -48.99 | -2.97 |
| កាការ ( ដុល្លារ/តោន ) | CIF New York (USA) | 9,055 | 7,731 | -1324 | -14.62 |

- កត់សំគាល់៖ តម្លៃកសិផលគ្រប់ប្រភេទមានការប្រែប្រួលទៅតាមប្រភេទនីមួយៗ នៅខែកក្កដា ឆ្នាំ២០២៤នេះ។
- តម្លៃពោត៖ នៅក្នុងខែកក្កដានេះ តម្លៃពោតនាំចេញនៅក្នុង Chicago បានថយចុះជាមធ្យម ១៣,៤៧ដុល្លារ/តោន (៧,៩៧%) ធៀបខែមិថុនា ដោយលក់ចេញក្នុងតម្លៃ ១៥៥,៥០ ដុល្លារ/តោន ( FOB, Chicago )។
- តម្លៃស្រូវសាលី៖ នៅក្នុងខែកក្កដានេះ តម្លៃស្រូវសាលីនាំចេញនៅ Chicago បានថយចុះជាមធ្យម ៣,៦៥ដុល្លារ/តោន( ៩,៦៦% ) ធៀបខែមិថុនា ដោយលក់ចេញក្នុងតម្លៃជាមធ្យម ២១២,៥០ដុល្លារ/តោន ( FOB Chicago )។
- តម្លៃសណ្តែកសៀង៖ នៅក្នុងChicagoនាខែកក្កដានេះ តម្លៃសណ្តែកសៀងនាំចេញបានថយ ៤,៣៧ដុល្លារ/តោន ( ១,០៦% ) ដោយលក់ចេញក្នុងតម្លៃមធ្យម ៤០៦,៧០ដុល្លារ/តោន, FOB Chicago ។
- តម្លៃប្រេងដូងប្រេង៖ តម្លៃប្រេងដូងប្រេងនៅទីផ្សារប្រទេសម៉ាឡេស៊ីនៅក្នុងខែកក្កដា ឆ្នាំ២០២៤បានកើន ១៧,០៨ ដុល្លារ/តោន ( ២,០៦% ) ដោយលក់ចេញក្នុងតម្លៃមធ្យម ៨៤៧,៦៩ដុល្លារ/តោន( FOB, Malaysia )។
- តម្លៃកាហ្វេ៖ នៅខែកក្កដានេះតម្លៃកាហ្វេនាំចេញគ្រប់ប្រភេទបានកើនឡើង ធៀបទៅនឹងខែបន្ទាប់។ នៅទីផ្សារ New York តម្លៃកាហ្វេរ៉ូប៊ូស្តាលក់ចេញបានកើន ២២៨,០០ដុល្លារ/តោន (៥,៣៤%) ដោយលក់ចេញក្នុងតម្លៃមធ្យម ៤.៤៩៨,០០ដុល្លារ/តោន, FOB (ទីផ្សារ New York) និងនៅក្រុងឡុងដ៍តម្លៃកាហ្វេអារ៉ាប៊ីកាលក់ចេញបានកើន ៩២១,៨៥ដុល្លារ/តោន( ១៨,១៧% ) ដោយលក់ចេញក្នុងតម្លៃមធ្យម ៥.៩៩៤,១៥ដុល្លារ/តោន( FOB, ទីផ្សារឡុងដុង )។ បច្ចុប្បន្ន ទីផ្សារកាហ្វេកំពុងស្ថិតក្នុងស្ថានភាពព្រួយបារម្ភអំពីអាកាសធាតុមិនអំណោយផលដល់ការដាំដុះនៅតំបន់មួយចំនួនលើពិភពលោក រួមទាំងប្រទេសប្រេស៊ីល ឥណ្ឌា និងវៀតណាមផងដែរ។ ជាក់ស្តែងក្នុងរយៈពេល ៥ខែ ដើមឆ្នាំនេះបរិមាណផលិតផលកាហ្វេនាំចេញរបស់វៀតណាមបានធ្លាក់ចុះ ៥,៨% ធៀបទៅនឹងឆ្នាំមុន។ នៅក្នុងការចំណាត់ថ្នាក់ទៅតាមប្រភេទកាហ្វេ គឺអារ៉ាប៊ីកាដណ្តើមបាន ៥៥% នៃបរិមាណផលិតផលកាហ្វេទូទាំងពិភពលោក និងចំនួន ៤៥% ជាប្រភេទកាហ្វេរ៉ូប៊ូស្តាផលិតនៅវៀតណាម ប្រេស៊ីល ឥណ្ឌូនេស៊ី និងUganda។ ហើយបរិមាណផលិតផលកាហ្វេពិភពលោកនៅរដូវឆ្នាំ២០២៣-២៤ នឹងទទួលបានចំនួន ១៧០លានបាវ និងតម្រូវការប្រើប្រាស់កើនជាមធ្យម ២% ។

- **ផលិតផលឧស្សាហកម្ម៖**

(ឯកតា៖ដុល្លារអាម៉េរិក/តោន)

| មុខទំនិញ | លក្ខខណ្ឌ ប្រគល់-ទទួល | ខែមិថុនា ឆ្នាំ២០២៤ | ខែកក្កដា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| ស្ករស | CIF London | 585.50 | 575.20 | -10.3 | -1.76 |
| កៅស៊ូប្រភេទRSS3 | FOB HCM(vn) | 1,985 | 1,894 | -91 | -4.58 |
| កៅស៊ូប្រភេទ RSS3 | FOBBangkok | 2,195 | 2,127 | -68 | -3.10 |
| កៅស៊ូប្រភេទ RSS3 | FOB Shanghai | 2,140 | 2,008 | -132 | -6.17 |
| កៅស៊ូប្រភេទ RSS3 | FOB Tokyo | 2,230 | 2,040 | -190 | -8.52 |
| កៅស៊ូប្រភេទ SMRCV | FOB Malaysia | 1,775 | 1,750 | -25 | -1.41 |
| កៅស៊ូប្រភេទ SIR20 | FOB Indonesia | 1,750 | 1,690 | -60 | -3.43 |

- កត់សំគាល់៖ តម្លៃទំនិញឧស្សាហកម្មមានការប្រែប្រួលទៅតាមប្រភេទនីមួយៗ ពិសេសតម្លៃស្ករស និងតម្លៃកៅស៊ូធម្មជាតិនៅក្នុងខែកក្កដា ឆ្នាំ២០២៤នេះ។
- តម្លៃស្ករស៖នៅក្នុងខែកក្កដានៅទីផ្សារឡុងដ៍តម្លៃស្ករសលក់ចេញបានថយចុះ១០,៣០ដុល្លារ/តោន(១,៧៦%)ធៀបទៅនឹងខែមិថុនា ដោយលក់ចេញក្នុងតម្លៃ ៥៧៥,២០ដុល្លារ/តោន(FOB, ឡុងដុង)។ នៅក្នុងដំណាក់កាលបច្ចុប្បន្នបណ្តារោងចក្រចំរាញ់ស្កររបស់ប្រេស៊ីល បានផលិតស្ករសបានចំនួន ២,៧លានតោន គឺទាបជាង ៧,៧២% ធៀបឆ្នាំមុន ហើយបរិមាណផលិតផលដើមអំពៅគាបយកស្ករបានថយចុះ ៣,៣៦% ចុះមកនៅក្នុងកំរិត ៤៥,២លានតោន និងបរិមាណផលិតផលអេតាណុល ថយ ០,២% ធៀបឆ្នាំមុន គឺស្ថិតក្នុងកំរិត ២,១២ពាន់លានលីត្រ។
- កៅស៊ូធម្មជាតិ៖ តម្លៃកៅស៊ូធម្មជាតិប្រភេទ RSS2 លក់ចេញនៅទីផ្សារតូក្យូប្រទេសជប៉ុននៅក្នុងខែកក្កដា នេះបានថយចុះជាមធ្យម១៩០ដុល្លារ/តោន(៨,៥២%) ធៀបទៅនឹងខែមិថុនាដោយលក់ចេញក្នុងតម្លៃមធ្យម ២.០៤០ដុល្លារ/តោន(FOB, តូក្យូ)។ យោងតាមព័ត៌មានបានឲ្យដឹងថា៖ នៅក្នុងត្រីមាសទី២ ឆ្នាំ២០២៤ ខឿនសេដ្ឋកិច្ចប្រទេសចិន (ប្រទេសប្រើប្រាស់កៅស៊ូធម្មជាតិច្រើនបំផុតលើពិភពលោក) ទទួលបានកំនើនតិចតួចបំផុតបើធៀបទៅនឹងរយៈពេល ៥ត្រីមាសកន្លងទៅ។ តាមរយៈមជ្ឈមណ្ឌលស្ថិតិជាតិរបស់ចិន(NBS)បានឲ្យដឹងថា៖ កំនើនយឺតយ៉ាវក្នុងត្រីមាសទី២ ដោយសារតែអាកាសធាតុមិនអំណោយផលខឿនសេដ្ឋកិច្ចកំពុងប្រឈមមុខនឹងផលលំបាកជាច្រើន។ ការដួលរលំទីផ្សារអចលនៈទ្រព្យបានធ្វើឲ្យបាត់បង់ទំនុកចិត្តពលរដ្ឋ និងការធ្វើអាជីវកម្ម។

- **ប្រេងឥន្ធនៈ**

(ឯកតា៖ ដុល្លារអាម៉េរិក/ធុង)

| មុខទំនិញ | លក្ខខណ្ឌប្រគល់-ទទួល | ខែមិថុនា ឆ្នាំ២០២៤ | ខែកក្កដា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| ប្រេងឆៅBrent | FOB (New York) | 85.58 | 85.35 | -0.23 | -0.27 |
| ប្រេង WTI | - | 82.17 | 81.91 | -0.26 | -0.32 |
| ហ្គាសGas($/mmbtu | F0B (VN) | 2.73 | 2.57 | -0.16 | -5.86 |

- កត់សំគាល់៖ នៅក្នុងខែកក្កដា ឆ្នាំ២០២៤នេះតម្លៃប្រេងឥន្ធនៈមានការប្រែប្រួលទៅតាមប្រភេទនីមួយៗ និងជាពិសេស តម្លៃប្រេងឆៅ។
- តម្លៃប្រេងឆៅ(Brent)៖ នៅទីផ្សារក្រុងញ៉ូយកតម្លៃប្រេងឆៅ Brent បានថយចុះ ០,២៣ដុល្លារ/ធុង(០,២៧%) ដោយលក់ចេញក្នុងតម្លៃជាមធ្យម ៨៥,៣៥ដុល្លារ/ធុង (FOB London)។ តម្លៃប្រាក់ដុល្លារអាមេរិកបានកើនឡើងក្នុងតម្លៃមួយខ្ពស់ធៀបទៅនឹងរូបិយប័ណ្ណមានតម្លៃរបស់ប្រទេសមួយចំនួន ដែលជាមូលហេតុបណ្តាលឲ្យតម្រូវការប្រើប្រាស់ប្រេងថយចុះ។ ទន្ទឹមនេះដែរ តាមតួលេខស្ថិតិ បានបង្ហាញថា ខឿនសេដ្ឋកិច្ចប្រទេសចិនទទួលបានកំណើនទាបជាង ៤,៧% នៅក្នុងត្រីមាសទី២ បានបង្កើននូវសេចក្តីព្រួយបារម្ភអំពីតម្រូវការប្រើប្រាស់ប្រេងរបស់ប្រទេសនេះ។

- **លោហៈ**

(ឯកតា៖ ដុល្លារអាម៉េរិក)

| មុខទំនិញ | លក្ខខណ្ឌប្រគល់-ទទួល | ខែមិថុនា ឆ្នាំ២០២៤ | ខែកក្កដា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| មាស ( $ / ounce ) | Hong Kong | 2,323.60 | 2,359.50 | 35.9 | 1.55 |
| មាស ( $ / ounce ) | London | 2,335.00 | 2,365.00 | 30 | 1.28 |
| មាស ( $ / ounce ) | New York | 2,332.00 | 2,367.00 | 35 | 1.50 |
| Platinum($/ounce) | - | 982.54 | 994.46 | 11.91 | 1.21 |
| Palladium($/ounce | New York | 1,000.95 | 964.30 | -36.65 | -3.66 |
| ប្រាក់($/troy ounce) | London | 29.26 | 31.02 | 1.76 | 6.02 |
| ប្រាក់($/troy ounce) | New York | 29.00 | 30.50 | 1.5 | 5.17 |

| | | | | | |
|---|---|---|---|---|---|
| ស្ពាន់($/tons) | FOB London | 9,858.00 | 9,599.00 | -259 | -2.63 |
| អាលុយមីញ៉ូម(Al) ($/tons) | - | ,521.50 | 2,524.50 | 3 | 0.12 |
| ស័ង្កសី(Zinc)($/tons) | FOB London | 2,873.50 | 2,937.50 | 64 | 2.23 |
| សំណប៉ាហាំង(Tin) ($/tons) | - | 33,086 | 32,739 | -347 | -1.05 |
| នីកែល(Nickel)(ដុល្លារ/តោន) | - | 19,168.63 | 16,942.74 | -2,225.89 | -11.61 |

- កត់សំគាល់៖ តម្លៃទំនិញលោហៈមានការប្រែប្រួលទៅតាមប្រភេទនីមួយៗ ជាពិសេសតម្លៃមាស។ នៅលើទីផ្សារអន្តរជាតិ តម្លៃមាសបានថយចុះ ធៀបទៅនឹងខែមិថុនា នៅទីក្រុងឡុងដ៍តម្លៃមាសលក់ចេញបានកើន ៣០,០០ដុល្លារ/Ounce (១,២៨%) ដោយលក់ចេញក្នុងតម្លៃ ២.៣៦៥,០០USD/Ounce និងនៅហុងកុង តម្លៃមាសលក់ចេញកើន ៣៥,៩០ដុល្លារ/ធុង (១,៥៥%) ដោយលក់ចេញក្នុងតម្លៃ ២.៣៥៩,៥០ USD/Ounce ។
  ប្រភព៖ (Website Vinanet)

# ២. អត្ថបទស្រាវជ្រាវ

## ទីផ្សារសូត្រកម្ពុជា៖

ទោះបីជាការដាំដើមមន និង ចិញ្ចឹមដង្កូវនាងបានកើតឡើងជាយូរលង់ណាស់មកហើយនៅក្នុងប្រទេសកម្ពុជាក៏ដោយដោយទម្លាប់នេះបានចាប់ផ្តើមតាំងពីសតវត្សរ៍ទី១៣។ នៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)សកម្មភាពនេះត្រូវបានបោះបង់ចោល និងរហូតមកដល់ទសវត្សរ៍ឆ្នាំ ១៩៩០ទើបសកម្មភាពនេះបានចាប់ផ្តើមឡើងវិញ បើទោះបីជាការផលិតសូត្របច្ចុប្បន្ននៅមានកម្រិតទាប ហើយការត្បាញភាគច្រើនប្រើប្រាស់សូត្រមកពីក្រៅប្រទេសក៏ដោយប៉ុន្តែតម្រូវការសូត្រក្នុងប្រទេសផ្តល់ឱកាស លើកទឹកចិត្តឲ្យមានការផលិតក្នុងស្រុក ដោយសារប្រទេសយើងមានអំណោយផលលើកំលាំងពលកម្ម ដីធ្លី និងអាកាសធាតុសមស្រប ហើយកម្ពុជាមានសក្តានុពលធំធេងជាប្រទេសផលិត។ ប៉ុន្តែការផលិតនេះមិនគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការប្រើប្រាស់ជាក់ស្តែងបច្ចុប្បន្នកម្ពុជាបាននាំចូលសូត្រឆៅ ៣៩៥តោនក្នុងមួយឆ្នាំៗ ក្នុងតម្លៃ៤៥លានដុល្លារមកពីប្រទេសចិន វៀតណាម និងផលិតដោយខ្លួនឯងត្រឹមតែ ៥តោនប៉ុណ្ណោះ។

ដើម្បីអភិវឌ្ឍន៍វិស័យសូត្រឲ្យអស់សក្តានុពលដែលមានស្រាប់ ចាំបាច់ត្រូវដោះស្រាយភាពខ្វះខាតសំខាន់ៗមួយចំនួន៖ ជំងឺលើដង្កូវនាងសមត្ថភាពស្ថាប័នមានកំរិតកំណត់ក្នុងការផ្គត់ផ្គង់ ពងដង្កូវនាងដែលមានសុខភាពល្អ ហើយការផលិតកូនដង្កូវនាងមិនបានល្អនៅតាមកសិដ្ឋាន បណ្តាលឲ្យកូនដង្កូវនាងងាប់យ៉ាងច្រើន ៥០%។ ទិន្នផលសំបុកដង្កូវនាងទាប ជំងឺពូជដង្កូវនាង មានគុណភាពទាប និងបច្ចេកទេសបុរាណ ជាមូលហេតុដែលនាំឲ្យផលិតកម្មសំបុកដង្កូវនាងទទួលបានទិន្នផលទាប។ សរសៃសូត្រមានគុណភាពទាប សមត្ថភាពបច្ចេកទេសស្រាវសរសៃសូត្រតាមបែបបុរាណដោយដៃ ពិបាកនឹងទទួលបានសរសៃសូត្រមានគុណភាពខ្ពស់ស្របទៅតាមស្តង់ដារអន្តរជាតិ។ កង្វះសមត្ថភាពបច្ចេកទេសទាំងរដ្ឋាភិបាលអង្គការក្រៅរដ្ឋាភិបាល និងអ្នកផលិតខ្វះខាតចំណេះដឹងសំខាន់ៗពីការស្រាវជ្រាវ ផលិតកម្មនិងគ្រប់គ្រង។ ការដឹកជញ្ជូនក្នុងរយៈចម្ងាយឆ្ងាយមានភាពមិនត្រឹមត្រូវតាមបច្ចេកទេសដែលធ្វើឲ្យកូនញាស់មាន

សុខភាពខ្សោយលូតលាស់យឺត និងងាយមានជំងឺ (កន្លងមកមជ្ឈមណ្ឌលសូត្រខ្មែរបានជួបឧបសគ្គដោយសារការដឹកជញ្ជូនពងដង្កូវនាងពីមជ្ឈមណ្ឌលសូត្រខ្មែរនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញទៅ សហគមន៍សូត្រខេត្តមណ្ឌលគិរីដែលមានសក្តានុពលក្នុងវិស័យកោសេយ្យវប្បកម្ម ។

មជ្ឈមណ្ឌលសូត្រខ្មែរត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០១៨ ក្រោមការផ្តួចផ្តើមរបស់ប្រធានក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ មជ្ឈមណ្ឌលសូត្រខ្មែរបានខិតខំពុះពារយ៉ាងសកម្ម ដើម្បីសម្រេចគោលដៅរបស់ខ្លួនជាពិសេសការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម កាត់បន្ថយការចំណាកស្រុកចូលរួមលើកកម្ពស់វប្បធម៌ និងប្រពៃណីជាតិ។ យន្តការដើម្បីសម្រេចសកម្មភាពគោលដៅរបស់មជ្ឈមណ្ឌលរួមមាន៖ ការបង្កើតអគារសម្រាប់ចិញ្ចឹម និងបង្កើន ពូជដង្កូវនាងការស្រាវជ្រាវបច្ចេកទេសជាមួយដៃគូរជាតិ អន្តរជាតិ និងការផ្តល់ចំណេះដឹងលើកោសេយ្យវប្បកម្ម(ការចិញ្ចឹមដង្កូវនាងសម្រាប់ផលិតសូត្រ)ដែលមានលក្ខណៈបច្ចេកទេសខ្ពស់ការចងក្រង និងគាំទ្របច្ចេកទេសសហគមសូត្រ និងស្វែងរកកាសទីផ្សារសម្រាប់ការផលិតសូត្រវិស័យសូត្រខ្មែរ ត្រៀមខ្លួនក្នុងការចាប់ផ្តើមប្រគួតប្រជៀតចូលទីផ្សារ ដើម្បីទាក់ទាញអ្នកវិនិយោគិន ដើម្បីធ្វើការអភិវឌ្ឍន៏វិស័យសូត្រឲ្យកាន់តែរីកចំរើន ខណៈដែលអ្នកជំនាញ និងរដ្ឋាភិបាលអំពាវនាវឲ្យមានការចូលរួមពីគ្រប់ភាគី។ វិស័យសូត្រត្រូវបានរីកដុះដាលពីខេត្តមណ្ឌលគីរីជាមួយនឹងការកើនឡើងពីការយកសូត្រចំការដង្កូវសូត្រពីមជ្ឈមណ្ឌលស្រាវជ្រាវដើម្បីធ្វើការផ្គត់ផ្គង់ទៅដល់ដៃកសិករដែលជាចំណូលដ៏ទាក់ទាញបើធៀបទៅនឹងវិស័យផ្សេងទៀត។ វិស័យសូត្រ អាចបង្កើនប្រាក់ចំណូលចន្លោះពី ៦០០ ទៅ៧០០ដុល្លារអាមេរិកសម្រាប់កសិករដែលមិនចាំបាច់ធ្វើចំណាកស្រុករឺធ្វើការនៅក្នុងឧស្សាហកម្មផ្សេងទៀតដែលនៅឆ្ងាយពីលំនៅដ្ឋានរបស់ពួកគេ។ បន្ទាប់ពីទទួលបានដង្កូវនាងពីការចិញ្ចឹម កសិករអាចយកដង្កូវនាងទាំងនោះទៅលក់បានចំណូលភ្លាមៗផងដែរការផលិតដង្កូវនាងចំណាយពេលជាមធ្យមមួយខែ រឺមួយខែកន្លះ ហើយអត្រាមរណៈរបស់ដង្កូវនាងបានធ្លាក់ចុះមកត្រឹម ៥% ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះខណៈដែលដង្កូវនាងត្រូវបានចិញ្ចឹមជាមួយនឹងបច្ចេកវិជ្ជាថ្មី។

តាមម្ចាស់អាជីវកម្មបានឲ្យដឹងថា៖ អ្នកស្រីបាននាំចូលអំបោះសូត្រចំនួន ៩៥% ជាវត្ថុធាតុដើមសម្រាប់ផលិតក្រណាត់សូត្រ និងផលិតផលសូត្រមកលក់តាមហាងនានា ហើយមួយចំនួនទៀតទិញពីផលិតករក្នុងស្រុក គឺពីខេត្តបន្ទាយមានជ័យ សៀមរាប និងផលិតផលតម្បាញនៅខេត្តតាកែវ។ ប្រហែលជា៨០% អតិថិជនដែលទិញផលិតផលសូត្រ គឺជាជនជាតិបរទេសដូចជា បារាំង និង២០% ជាជនជាតិខ្មែរ។ ម្ចាស់អាជីវកម្មបានបន្ថែមទៀតថាយើងចូលចិត្តអំបោះសូត្រដែលផលិតក្នុងស្រុក ផលិតផលនាំចូលងាយស្រួលក្នុងការគ្រប់គ្រងស្តុក និងឆ្លើយតបអតិថិជនទាន់ពេលវេលា។ ជាឧទាហរណ៍នៅពេលដែលអតិថិជនបញ្ជាទិញក្រណាត់សូត្រ យើងមានវត្ថុធាតុដើមគ្រប់គ្រាន់គឺយើងអាចបំពេញតម្រូវការទាន់ពេល។ វាជាការលំបាកក្នុងការគ្រប់គ្រងស្តុក វត្ថុធាតុដើមដែលនាំចូលព្រោះយើងមិនដឹងថាត្រូវធ្វើអ្វីនៅពេលដែលវាអស់ពីស្តុក ហើយតម្លៃរបស់វាមានការប្រែប្រួល គ្មានស្ថេរភាព និងគុណភាពនៃអំបោះសូត្រផលិតក្នុងស្រុក គឺមានការប្រកួតប្រជែង។

ទន្ទឹមនេះវិស័យសូត្រកម្ពុជា ក៏ទទួលបានការស្វាគមន៍ និងលើកទឹកចិត្តឲ្យវិនិយោគិនបរទេសចូលមកវិនិយោគលើវិស័យសូត្រនៅកម្ពុជាឲ្យកាន់តែច្រើន ខណៈដែលកម្ពុជាកំពុងសម្រេចបានសមិទ្ធិផលជាច្រើន ក្នុងជំរុញឲ្យវិស័យនេះមានទីផ្សារកាន់តែទូលាយ។ ការលើកឡើងនេះ ត្រូវបានធ្វើឡើងនៅទីស្តីការក្រសួងពាណិជ្ជកម្ម ក្នុងជំនួបរវាងឯកឧត្តមម៉ៅ ថូរ៉ា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ជាមួយលោក Zhang Quoqiang ប្រធានសហព័ន្ធសូត្រអន្តរជាតិ(ISU) និងជាប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន Zhejiang Cathaya Group ដែលមកពីសាធារណៈរដ្ឋប្រជាមានិតចិន ការចូលរួមពីសំណាក់គណៈកម្មការជំរុញ និងអភិវឌ្ឍន៏វិស័យសូត្រកម្ពុជា (SDC) តំណាងសមាគមសូត្រ និងផ្នែកឯកជនជាច្រើនរូប។

ផលិតផលសូត្រនៅកម្ពុជា អាចនឹងកើនឡើងនៅពេលអនាគត ប៉ុន្តែវានឹងរំពឹងទៅលើទីផ្សារខណៈដែលកសិករនៅតែប្រឈមនឹងការខ្វះខាតបទពិសោធន៍ក្នុងការប្រកួតប្រជែងជាមួយទីផ្សារសូត្រពីបរទេស៕

ប្រភព: គេហទំព័រក្រសួងកសិកម្ម

# ៣. ព័ត៌មានរបស់ក្រសួងពាណិជ្ជកម្ម

**លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួង ដើម្បីត្រៀមលក្ខណៈរៀបចំចូលរួមពិព័រណ៍ពិភពលោក ២០២៥ និងពិព័រណ៍ចិន-អាស៊ានលើកទី២១**

(ភ្នំពេញ)៖ នាព្រឹកថ្ងៃចន្ទ ទី១៥ ខែកក្កដា ឆ្នាំ២០២៤ នៅទីស្តីការក្រសួងពាណិជ្ជកម្ម លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិបានអញ្ជើញជាអធិបតីភាពដឹកនាំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងក្នុងគោលបំណងត្រៀមលក្ខណៈរៀបចំចូលរួមពិព័រណ៍ចិន-អាស៊ានលើកទី២១ ដែលនឹងប្រព្រឹត្តិទៅចាប់ពីថ្ងៃទី២៤-២៨ ខែកញ្ញា ឆ្នាំ ២០២៤ នៅទីក្រុងណាននីង តំបន់ស្វយ័តក្វាងស៊ី សាធារណរដ្ឋប្រជាមានិតចិន និងពិព័រណ៍ពិភពលោក ២០២៥ ដែលនឹងប្រព្រឹត្តិទៅចាប់ពីថ្ងៃទី១២ ខែមេសា ដល់ ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៥នៅទីក្រុងអូសាកា ប្រទេស ជប៉ុន ដោយវត្តមានអញ្ជើញចូលរួមដោយឯកឧត្តម លោកជំទាវ អនុប្រធាន សមាជិក សមាជិកានៃគណៈកម្មការអន្តរក្រសួង និងឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មជាច្រើនរូប។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/news/1957

**លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម តំណាងរាជរដ្ឋាភិបាល បានអញ្ជើញចូលរួមជាអធិបតីថ្លែងសុន្ទរកថាអបអរសាទរ និងសំណេះសំណាលក្នុងពិធីជប់លៀង ក្នុងឱកាសបុណ្យជាតិ ខួបលើកទី១២៦ និងខួបលើកទី៦៧ នៃទំនាក់ទំនងការទូតកម្ពុជា-ហ្វីលីពីន**

(ភ្នំពេញ)៖ នាល្ងាចថ្ងៃសុក្រ ទី១៩ ខែកក្កដា ឆ្នាំ២០២៤ នៅសណ្ឋាគារ Rosewood ភ្នំពេញ លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម តំណាងរាជរដ្ឋាភិបាល បានអញ្ជើញចូលរួមជាអធិបតីថ្លែងសុន្ទរកថាអបអរសាទរ និងសំណេះសំណាលក្នុងពិធីជប់លៀង ក្នុងឱកាសបុណ្យជាតិ ខួបលើកទី១២៦ និងខួបលើកទី៦៧ នៃទំនាក់ទំនងការទូតកម្ពុជា-ហ្វីលីពីន។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/news/1978

**លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានអនុញ្ញាតជូនលោក កាយ ឡុត ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយកក្រុមហ៊ុនសិប្បករអង្គរ ឯ.ក និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារអំពីការគាំទ្ររបស់ក្រសួងពាណិជ្ជកម្មក្នុងការអភិវឌ្ឍន៍វិស័យសូត្រ ព្រមទាំងស្វែងយល់ឱកាសដែលក្រុមហ៊ុនអាចចូលរួមចំណែកក្នុងផែនការអភិវឌ្ឍវិស័យសូត្រនេះ**

(ភ្នំពេញ)៖ នាព្រឹកថ្ងៃចន្ទ ទី២២ ខែកក្កដា ឆ្នាំ២០២៤ នៅទីស្តីការក្រសួងពាណិជ្ជកម្ម លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានអនុញ្ញាតជូនលោក កាយ ឡុត ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយកក្រុមហ៊ុនសិប្បករអង្គរឯ.ក និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារអំពីការគាំទ្ររបស់ក្រសួងពាណិជ្ជកម្មក្នុងការអភិវឌ្ឍន៍វិស័យសូត្រ ព្រមទាំងស្វែងយល់ឱកាសដែលក្រុមហ៊ុនអាចចូលរួមចំណែកក្នុងផែនការអភិវឌ្ឍវិស័យសូត្រនេះ។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/news/1983

**ឯកឧត្តម ពេជ ឫទ្ធី រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ជួបពិភាក្សាការងារជាមួយ លោក** Wayne C. Farmer **ប្រធានក្រុមប្រឹក្សាធុរកិច្ចកាណាដា-អាស៊ាន** (Canada-ASEAN Business Council)

(ភ្នំពេញ)៖ នារសៀលថ្ងៃចន្ទ ទី១៥ ខែកក្កដា ឆ្នាំ២០២៤ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ឯកឧត្តម ពេជ ឫទ្ធី រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម តំណាងដ៏ខ្ពង់ខ្ពស់របស់ លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានអញ្ជើញដឹកនាំគណៈប្រតិភូក្រសួងពាណិជ្ជកម្ម ជួបពិភាក្សាការងារជាមួយ លោក Wayne C. Farmer ប្រធានក្រុមប្រឹក្សាធុរកិច្ចកាណាដា-អាស៊ាន (Canada-ASEAN Business Council — CABC) និងគណៈប្រតិភូ ដើម្បីពិភាក្សាអំពីកាលានុវត្តភាពពាណិជ្ជកម្ម និងវិនិយោគរបស់កាណាដានៅកម្ពុជា ជាពិសេសក្នុងវិស័យ កសិធុរកិច្ច ថាមពល និងហេដ្ឋារចនាសម្ព័ន្ធ។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/news/1965

**ឯកឧត្តម អ៊ុក ប្រជា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងឯកឧត្តម សួន វិជ្ជា បានជួបប្រជុំទ្វេភាគីជាមួយលោក** Alejandro ROCA CAMPANA **នាយកជាន់ខ្ពស់ នៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក** (WIPO) **និងសហការី**

(ហ្សឺណែវ ស្វីស)៖ នាថ្ងៃអង្គារ ទី១៦ ខែកក្កដា ឆ្នាំ២០២៤ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ឯកឧត្តម អ៊ុក ប្រជា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងឯកឧត្តម សួន វិជ្ជា បានជួបប្រជុំទ្វេភាគីជាមួយលោក Alejandro ROCA CAMPANA នាយកជាន់ខ្ពស់ នៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) និងសហការី។

ឯកឧត្តមរដ្ឋលេខាធិការ បានថ្លែងអំណរគុណ និងលើកឡើងពីកិច្ចសហប្រតិបត្តិការរវាង កម្ពុជា និងWIPO និងជំនួយបច្ចេកទេសក្នុងការរៀបចំច្បាប់ និងការអភិវឌ្ឍប្រព័ន្ធកម្មសិទ្ធិបញ្ញានៅកម្ពុជា ការផ្តល់ប្រពន្ធ័រដ្ឋបាលកម្មសិទ្ធិឧស្សាហកម្ម (IPAS) និងបានជម្រាបជូនអង្គប្រជុំអំពីស្ថានភាព និងការវិវត្តកម្មសិទ្ធិបញ្ញានៅកម្ពុជា គោលនយោបាយជាតិកម្មសិទ្ធិបញ្ញាឆ្នាំ២០២៣-២០២៨ អនុស្សារណៈនៃការយោគយល់គ្នារវាង គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/news/1862

**ឯកឧត្តម បួន សារៈមុនី រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម បានដឹកនាំកិច្ចប្រជុំ ជាមួយតំណាងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ** (IFC) **និងតំណាងក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ ខេមបូឌា** (CBC) **ដើម្បីពិនិត្យ និងពិភាក្សាលើការគាំទ្ររបស់** IFC **លើប្រព័ន្ធតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា** (SETFO)

(ភ្នំពេញ)៖ នារសៀលថ្ងៃចន្ទ ទី២២ ខែកក្កដា ឆ្នាំ២០២៤ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ឯកឧត្តម បួន សារៈមុនី រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម បានដឹកនាំកិច្ចប្រជុំ ជាមួយតំណាងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និងតំណាងក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ ខេមបូឌា (CBC) ដើម្បីពិនិត្យ និងពិភាក្សាលើការគាំទ្ររបស់ IFC លើប្រព័ន្ធតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា (SETFO)។

ក្នុងកិច្ចប្រជុំនេះដែរ ឯកឧត្តមរដ្ឋលេខាធិការ បានចែករំលែកពីវឌ្ឍនភាពការងារប្រព័ន្ធ SETFO របស់ក្រសួងពាណិជ្ជកម្ម និងការប្តេជ្ញាចិត្តរបស់ក្រសួងក្នុងការជម្រុញការងារនេះឱ្យបានទាន់ពេលវេលា ដើម្បីសម្រួលដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា ជំរុញប្រតិបត្តិការធនាគារ និងការផ្តល់ហិរញ្ញប្បទានគ្រប់ប្រភេទប្រកបដោយប្រសិទ្ធភាព។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/news/1985

# ៤.ព័ត៌មានទីផ្សារអន្តរជាតិ

## ▲ ទីផ្សារនាំចេញទំនិញវៀតណាមឆ្នាំ២០២៣៖

ក្នុងបណ្តាឆ្នាំកន្លងទៅ កិច្ចសហប្រតិបត្តិសេដ្ឋកិច្ច ពាណិជ្ជកម្មរវាងកម្ពុជា វៀតណាម ទទួលបាននូវសមិទ្ធិផលល្អប្រសើរ និងប្រកបដោយអត្ថន័យជ្រាលជ្រៅ ហើយទន្ទឹមនោះវៀតណាម ក៏ជាដៃគូរពាណិជ្ជកម្មលំដាប់ទីមួយរបស់កម្ពុជាផងដែរ។ តាមតួរលេខថ្មីបំផុតរបស់នាយកដ្ឋានគយវៀតណាមបានអោយដឹងថា នៅក្នុងខែឧសភា ឆ្នាំ២០២៤ ទំនិញនាំចូលពីវៀតណាមមកកម្ពុជាគិតជាទឹកប្រាក់មានចំនួន ៤៥៤,៤លានដុល្លារគឺកើន ៩,៨% ធៀបខែបន្ទាប់។ បើគិតជារួមក្នុងរយៈពេល ៥ខែ ដើមឆ្នាំ២០២៤ ទឹកប្រាក់នាំចេញទទួលបាន ២,១ពាន់លានដុល្លារ គឺកើន១,៩% ធៀបទៅនឹងរយៈពេលដូចគ្នានាឆ្នាំមុន។ មុខទំនិញវាយនភណ្ឌ គឺជាមុខទំនិញនាំមុខនៅក្នុងចំណោមមុខទំនិញនាំចូលទៅកាន់ទីផ្សារកម្ពុជា។ នៅក្នុងខែឧសភា ឆ្នាំ២០២៤ដោយទទួលបានទឹកប្រាក់សរុបចំនួន ៨១,៦លានដុល្លារ គឺកើន ១៨,៥% ធៀបខែបន្ទាប់ និងសរុបរយៈពេល៥ខែដើមឆ្នាំ២០២៤ ទទួលបានទឹកប្រាក់សរុបចំនួន ៣៥០,៣លានដុល្លារ ស្មើនឹង ១៦,៥%។ មុខទំនិញបន្ទាប់ គឺដែកគ្រប់ប្រភេទ បើគិតជារួមនៅក្នុងខែឧសភា ឆ្នាំ២០២៤ ទទួលបានទឹកប្រាក់សរុប ៦៩,៩លានដុល្លារ និងនៅក្នុងរយៈពេល៥ខែ ដើមឆ្នាំ២០២៤ ទទួលបានទឹកប្រាក់សរុប ៣០២,១ លានដុល្លារស្មើ១៤,២% នៃបរិមាណនាំចេញសរុប។ បណ្តាមុខទំនិញបន្ទាប់ដែលទទួលបានកំណើននាំចេញខ្ពស់ធៀបឆ្នាំបន្ទាប់មាន៖ ផលិតផលពីសារៈធាតុកំហាប់កើន ៤០% គ្រឿងម៉ាស៊ីន គ្រឿងបន្លាស់ គ្រឿងបង្គុំ និងឧបករណ៍ផ្សេងទៀតកើន ៤៥,២% ឈើ និងផលិតផលអំពីឈើកើន ៥៤% ផលិតផលពីកៅស៊ូកើន ៧៧,២% កាហ្វេកើន ៧៨,៧%។

### តួរលេខទំនិញវៀតណាមនាំចូលកម្ពុជាឆ្នាំ២០២៤

(ប្រកាសថ្មីបំផុតរបស់នាយកដ្ឋានគយវៀតណាម ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤)

| ទំនិញ | ខែឧសភា ២០២៤ | ធៀបខែមេសា ២០២៤(%) | ៥ខែដើម ឆ្នាំ២០២៤ | (+/-)ធៀបឆ្នាំ ២០២៣(%) | (%) |
|---|---|---|---|---|---|
| សរុប(USD) | 454,461,691 | 9.8 | 2,116,995,625 | 1.91 | 100 |
| មុខទំនិញវាយនភ័ណ្ឌ | 81,649,647 | 18.52 | 350,333,205 | 1.43 | 16.55 |
| ដែកគ្រប់ប្រភេទ | 69,956,279 | 41,26 | 302,120,915 | -10.09 | 14.27 |
| ប្រេងសាំងគ្រប់ប្រភេទ | 35,086,325 | 24.69 | 163,623,945 | -27.88 | 7.73 |
| វត្ថុធាតុដើមបន្ទាប់បន្សំ ស្បែកសត្វ អំបោះ ក្រណាត់សូត្រ ........... | 33,031,316 | -0.37 | 155,542,256 | 27.38 | 7.35 |
| ផលិតផលសារធាតុកំហាប់ | 20,508,985 | 9.8 | 89,231,790 | 40.04 | 4.22 |
| ជីដាក់ដំណាំគ្រប់ប្រភេទ | 17,087,550 | 1.72 | 76,479,075 | -19.89 | 3.61 |

| ទំនិញ | ខែឧសភា ២០២៤ | ធៀបខែមេសា ២០២៤(%) | ៥ខែដើម ឆ្នាំ២០២៤ | (+/-)ធៀបឆ្នាំ ២០២៣(%) | (%) |
|---|---|---|---|---|---|
| ក្រដាស និងផលិតផល ពី ក្រដាស | 14,152,403 | 20.15 | 64,078,182 | 1.48 | 3.03 |
| លោហៈធម្មតា ផលិតផល | 13,555,229 | 0.25 | 59,235,232 | 36.67 | 2.8 |
| ផលិតផលអំពីដែក | 14,755,711 | 92.39 | 48,887,542 | -21.51 | 2.31 |
| ចំណីសត្វ វត្ថុធាតុដើម | 9,480,828 | 19.7 | 47,796,169 | -33.18 | 2.26 |
| លោហៈធម្មតា ផលិតផល | 8,431,516 | 11.73 | 95,733,073 | -26.8 | 1.96 |
| ម៉ាស៊ីន គ្រឿងបន្លំ គ្រឿងបន្លាស់និងឧបករណ៍ផ្សេង | 7,187,176 | -68.93 | 47,563,062 | 45.22 | 2.23 |
| ផលិតផលគីមី | 11,787,937 | 24.59 | 46,807,050 | 14.3 | 2.21 |
| សូត្រអំបោះគ្រប់ប្រភេទ | 9,172,620 | 0.15 | 42,659,857 | 23.13 | 2.02 |
| នំ ស្ករគ្រាប់គ្រប់ប្រភេទ | 5,549,255 | -1.51 | 27,962,360 | 0.33 | 1.32 |
| សារជាតុគីមី | 3,489,229 | 0.49 | 19,236,212 | 12.36 | 0.91 |
| ឈើ និងផលិតផលពីឈើ | 5,258,875 | 39.55 | 18,055,091 | 54.03 | 0.85 |
| ខ្សែចំលងចរន្ត | 3,638,832 | -6.39 | 17,593,247 | 28.34 | 0.83 |
| អង្ករ | 3,568,919 | 47.11 | 16,033,464 |  | 0.76 |
| សារជាតុកំហាប់ និង ផលិតផល | 4,031,971 | 49.25 | 14,136,051 | 36.09 | 0.67 |

| ទំនិញ | ខែឧសភា ២០២៤ | ធៀបខែមេសា ២០២៤(%) | ៥ខែដើម ឆ្នាំ២០២៤ | (+/-)ធៀបឆ្នាំ ២០២៣(%) | (%) |
|---|---|---|---|---|---|
| មធ្យោបាយធ្វើចរាចរ និងគ្រឿងបន្លាស់ | 2,678,695 | -7.19 | 13,168,785 | -16.12 | 0.62 |
| ទំនិញជលផល | 3,127,836 | 21.07 | 12,706,483 | -39.71 | 0.6 |
| បន្លែផ្លែឈើ | 900,734 | 2.89 | 5,608,081 | 13.22 | 0.26 |
| ប៉ស៊ីឡែន និងផលិតផលពីប៉ស៊ីឡែន | 504,714 | -44.07 | 5,608,081 | 28.59 | 0.25 |
| កុម្ភកាភ័ណ្ឌ(ស្មុន) | 970,989 | 61.41 | 4,218,843 | -31.09 | 0.2 |
| ផលិតផលធ្វើពីកៅស៊ូ | 904,404 | 6.17 | 3,553,904 | 77.23 | 0.17 |
| គ្រឿងសង្ហារឹមមិនធ្វើពីឈើ | 546,521 | -24.04 | 3,399,640 | 61.98 | 0.16 |
| កាហ្វេ | 815,720 | 49.75 | 2,998,094 | 78.71 | 0.14 |
| chinhke និងស៊ីម៉ាំង | 286,520 | 46 | 1,395,364 | -45.02 | 0.07 |
| ទំនិញផ្សេងទៀត | 81,676,492 | -3.63 | 457,381,298 | 14.99 | 21.61 |

# អំពីព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម

ព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម គឺជាព្រឹត្តិបត្របោះពុម្ពផ្សាយដោយនាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម។ ព្រឹត្តិបត្រនេះប្រមូលផ្តុំនូវមាតិកាសំខាន់ៗរួមមាន ស្ថិតិព័ត៌មានពាណិជ្ជកម្ម សន្ទស្សន៍ថ្លៃទំនិញចាំបាច់ ព័ត៌មានតម្លៃទំនិញសំខាន់ៗ លើទីផ្សារពិភពលោក និងអត្ថបទស្រាវជ្រាវ។

## សមាសភាពថ្នាក់ដឹកនាំ និងក្រុមការងារ

១- ឯកឧត្តម ប៉ែន សុវិជាតិ

២- លោកជំទាវ សេរី បូរាពេជ្រ

៣- លោក គន់ ឌីរ៉ង់

៤- លោកស្រី ឡុង លាបភា

៥- លោកស្រី ធន សាល័ក្ខណ៍

៦- លោកស្រី ចាច់ ម៉ារីយ៉ា

៧- លោក យឹម រ៉ុម

៨- លោក ស៊ិន សុខហេង

៩- លោក សេង សុគន្ធា (អ្នករចនា)

## សូមស្កេន QR Code ដើម្បីភ្ជាប់ទៅ បណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម

Website
www.moc.gov.kh

Facebook
@moc.gov.kh

Telegram
@mocnewsfeed

YouTube
@mocgovkhcambodia

X Account
@MoCCambodia

ដីឡូត៍ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣ បេ) ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ភ្នំពេញ ១២១០២

Lot 19-61 MOC Road (113B Road) Phum Teuk Thla , Sangkat Teuk Thla , Khan Sen Sok, Phnom Penh 12102

Email : dpsti.bulletin@moc.gov.kh